អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ការតែងតាំងថ្មីនៅក្នុងផ្នែកកិច្ចការសាធារណៈនៃអ.វ.ត.ក.

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) សូមជូនដំណឹង អំពីការផ្លាស់ប្តូរដើម្បីបំពេញបន្ថែមតំណែងដែលនៅទំនេរ និងដើម្បីពង្រឹងផ្នែកកិច្ចការសាធារណៈ របស់អ.វ.ត.ក.។

-លោក**ឌឹម សុវណ្ណារុំ** ដែលបានបម្រើការជាអ្នកនាំពាក្យសាលាក្តីខ្មែរក្រហម ត្រូវបានតែងតាំង ជា មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងបន្ថែមផ្នែកព័ត៌មានសាធារណៈ ប្រព័ន្ធផ្សព្វផ្សាយ និង ផ្នែកផ្សព្វផ្សាយរបស់អ.វ.ត.ក. លោក**ហ៊ុយ វណ្ណៈ** ត្រូវបានតែងតាំឲ្យកាន់តំណែងថ្មីជាមន្ត្រីកិច្ចការ សាធារណៈ។ មុនពេលបំពេញការងារនៅ អ.វ.ត.ក លោក វណ្ណៈ គឺជានិពន្ធនាយកព័ត៌មាននៃបណ្តាញ ស្ថានីយ៍ទូរទស្សន៍កម្ពុជា (ស៊ីធីអិន) ហើយមុននេះទៀត លោកគឺជាអ្នកយកព័ត៌មានឲ្យវិទ្យុអាស៊ីសេរី។ ដោយធ្លាប់បម្រើការជាអ្នកស្រាវជ្រាវ និងនិពន្ធសៀវភៅនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកហ៊ុយ វណ្ណៈ មានការយល់ដឹងជ្រៅជ្រះអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោក វណ្ណៈ មានសញ្ញាប័ត្រអនុបណ្ឌិតលើមុខវិជ្ជាទំនាក់ទំនងសាកលពីសាកលវិទ្យាល័យ វ៉ាត់ហ្គឹត នៅរដ្ឋញូវចឺស៊ី សហរដ្ឋអាមេរិក។

ក្នុងគោលបំណងលើកកម្ពស់និងពង្រឹងការងារផ្សព្វផ្សាយព័ត៌មានដល់សាធារណជនក៏ដូចជាទៅតាមបណ្តាខេត្ត និងពង្រឹងទំនាក់ទំនងជាមួយបណ្តាញព័ត៌មាន អ.វ.ត.ក ក៏បានតែងតាំងលោក **នេត្រ ភក្ត្រា** ជាមន្ត្រីនាំពាក្យនៃអ.វ.ត.ក.។ ពីមុន លោក ភក្ត្រា គឺជានាយកគ្រប់គ្រងការីនិពន្ធនៃ សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍ ភាសាខ្មែរ។ លោក ភក្ត្រា មានបទពិសោធន៍រយៈពេល៩ឆ្នាំក្នុង វិស័យសារព័ត៌មាននៅសារព័ត៌មានភ្នំពេញ ប៉ុស្តិ៍ វិទ្យុបារាំងអន្តរជាតិ ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ ស៊ីធីអិន សារព័ត៌មានមេគង្គ ថៃមស៍ និងសារព័ត៌មានសំណេរថ្មី។ លោក ភក្ត្រាមានសញ្ញាប័ត្រ បរិញ្ញាប័ត្រលើមុខវិជ្ជាសារព័ត៌មាន និងវិធីសាស្ត្របង្រៀនភាសាបារាំង ពីវិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ 0២៣
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ត: ៦១៦៩
សារអេឡិកត្រូនិក: olsenl@un.org

**ឌឹម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨៨ 0៩៤
សារអេឡិចត្រូនិក:
dim.sovannarom@eccc.gov.kh

**យូកូ ម៉ែដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ត: ៦១៣៩
សារអេឡិកត្រូនិក: maeday@un.org